ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១២៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកែសម្រួលមាត្រា៦ មាត្រា៧ មាត្រា៩ និងមាត្រា១៣ នៃអនុក្រឹត្យលេខ ៨៤ អនក្រ.បក ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៩ ស្តីពីការបង្កើតគ្រឹះស្ថានអង្គរ ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១២/០០៤ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលទ្ធកម្មសាធារណៈ

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៥ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥១៨/៥៩០ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៨ ស្តីពីការកែសម្រួលមាត្រាមួយចំនួននៃព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៥ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៨៤អនក្រ.បក ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៩ ស្តីពីការបង្កើតគ្រឹះស្ថានអង្គរ ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងទេសចរណ៍

## សម្រេច

**មាត្រាមួយ:**

មាត្រា៦ មាត្រា៧ មាត្រា៩ និងមាត្រា១៣ នៃអនុក្រឹត្យលេខ ៨៤ អនក្រ.បក ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៩ ស្តីពីការបង្កើតគ្រឹះស្ថានអង្គរ ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវបានកែសម្រួល ដូចខាងក្រោម÷

**មាត្រា៦.-ថ្មី**

គ្រឹះស្ថានអង្គរ(**គ.ស.អ.**)មានសមាជិកក្រុមប្រឹក្សាភិបាលចំនួន ៧ រូប ដែលមានសមាសភាពដូចតទៅ÷

| | |
|---|---|
| - តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ប្រធាន |
| - តំណាងក្រសួងទេសចរណ៍ | អនុប្រធាន |
| - តំណាងក្រសួងវប្បធម៌និងវិចិត្រសិល្បៈ | សមាជិក |
| - តំណាងសាលាខេត្តសៀមរាប | សមាជិក |
| - អគ្គនាយកនៃអាជ្ញាធរជាតិអប្សរា | សមាជិក |
| - អគ្គនាយកនៃ **គ.ស.អ.** | សមាជិក |
| - តំណាងបុគ្គលិកនៃ **គ.ស.អ.** | សមាជិក |

ក្រុមប្រឹក្សាភិបាលនៃ **គ.ស.អ.** ត្រូវបង្កើតក្នុងរយៈពេលយ៉ាងយូរ ១ (មួយ)ខែ បន្ទាប់ពីកាលបរិច្ឆេទនៃការបង្កើត **គ.ស.អ.** តាមសំណើរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៧.-ថ្មី**

តំណាងបុគ្គលិកនៃ **គ.ស.អ.**១ (មួយ) រូប គឺជាសមាជិកក្រុមប្រឹក្សាភិបាលស្វ័យប្រវត្តិ ដែលត្រូវបានជ្រើសរើសដោយការបោះឆ្នោតតាមលក្ខណៈប្រជាធិបតេយ្យ ក្នុងចំណោមបុគ្គលិកសម្រាប់អាណត្តិ៣ (បី)ឆ្នាំ។

តំណាងបុគ្គលិកត្រូវក្លាយជាសមាជិកក្រុមប្រឹក្សាភិបាលចាប់ពីថ្ងៃជាប់ឆ្នោត ដោយមិនចាំបាច់មានការតែងតាំងឡើយ។

តំណាងបុគ្គលិកនេះ ត្រូវបានជ្រើសរើសដោយការបោះឆ្នោត។ អ្នកមានសិទ្ធិបោះឆ្នោតសម្រាប់អាណត្តិនៃក្រុមប្រឹក្សាភិបាលនីមួយៗ ជាបុគ្គលិកទាំងអស់ដែលមានសិទ្ធិបោះឆ្នោត តាមការសម្រេចរបស់អគ្គនាយក។

តំណាងនេះ ត្រូវជ្រើសរើសពីក្នុងចំណោមបុគ្គលិករបស់ **គ.ស.អ.** ដោយសម្លេងគាំទ្រភាគច្រើនដាច់ខាតស្របតាមលក្ខខណ្ឌវិនិច្ឆ័យដូចខាងក្រោម÷

- មានសញ្ជាតិខ្មែរ ហើយមានអាយុយ៉ាងតិច ២៥ឆ្នាំ និងយ៉ាងច្រើន ៥៥ឆ្នាំ
- បម្រើការងារយ៉ាងតិច ៥ (ប្រាំ)ឆ្នាំ និងយកចិត្តទុកដាក់ក្នុងការការពារផលប្រយោជន៍ឱ្យបុគ្គលិកទាំងអស់
- មានកិរិយាមារយាទល្អ
- ពុំធ្លាប់ទទួលការផ្តន្ទាទោសពីបទមជ្ឈិម ឬបទឧក្រិដ្ឋពាក់ព័ន្ធនឹងទំនុកចិត្ត និងសមត្ថភាពវិជ្ជាជីវៈ
- មានសមត្ថភាព បទពិសោធវិជ្ជាជីវៈគ្រប់គ្រាន់តាមសំណូមពរ និងលក្ខខណ្ឌរបស់ **គ.ស.អ.**។

នីតិវិធីសម្រាប់ការបោះឆ្នោតតំណាងបុគ្គលិក ជាសមាជិកក្រុមប្រឹក្សាភិបាលសម្រាប់អាណត្តិនីមួយៗនៃ **គ.ស.អ.** ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់អគ្គនាយក។

ក្រៅពីសមាជិកក្រុមប្រឹក្សាភិបាលស្វ័យប្រវត្តិ សមាជិកក្រុមប្រឹក្សាភិបាលដទៃទៀត ត្រូវមានអាណត្តិ ៣ (បី)ឆ្នាំ ដែលត្រូវតែងតាំង និងបញ្ចប់មុខតំណែងដោយអនុក្រឹត្យ តាមសំណើរបស់ក្រសួង ស្ថាប័ន ដែលសមាជិកនោះតំណាងឱ្យ។ សមាជិកក្រុមប្រឹក្សាភិបាល អាចតែងតាំងបន្តអាណត្តិសារជាថ្មីទៀតបាន ដោយអនុក្រឹត្យ។

**មាត្រា៩.-ថ្មី**

សមាសភាពក្រុមប្រឹក្សាភិបាលអាចបញ្ចប់មុនអាណត្តិ តាមសំណើរបស់ក្រសួង ស្ថាប័នតំណាង ក្នុងករណីដែលសមាជិកក្រុមប្រឹក្សាភិបាលនោះ មានជាអាទិ៍ បាត់បង់ភាពស្របច្បាប់ជាតំណាងក្រសួង ស្ថាប័នតំណាងបុគ្គលិករបស់ **គ.ស.អ.** ទទួលមរណភាព សុំលាឈប់ជាលាយលក្ខណ៍អក្សរ បាត់បង់សម្បទាវិជ្ជាជីវៈដោយមានលិខិតបញ្ជាក់ពីក្រសួង ស្ថាប័នមានសមត្ថកិច្ច ឬត្រូវបានផ្តន្ទាទោសឱ្យជាប់ពន្ធនាគារពីបទឧក្រិដ្ឋ ឬបទមជ្ឈិមណាមួយ។

ក្រុមប្រឹក្សាភិបាលនីមួយៗ ត្រូវបន្តនិរន្តរភាពការងាររបស់ខ្លួនរហូតដល់មានការតែងតាំងក្រុមប្រឹក្សាភិបាលថ្មី។ ក្រុមប្រឹក្សាភិបាលអាណត្តិថ្មី ត្រូវតែងតាំងយ៉ាងយូរបំផុត ១ (មួយ)ខែ ក្រោយការបញ្ចប់អាណត្តិក្រុមប្រឹក្សាភិបាលចាស់។ មុនការបញ្ចប់អាណត្តិក្រុមប្រឹក្សាភិបាល ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវរៀបចំសំណើទៅកាន់ក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីចាត់បញ្ជូនបេក្ខភាពសមាជិកក្រុមប្រឹក្សាភិបាលអាណត្តិថ្មី។ ការតែងតាំងសមាជិកក្រុមប្រឹក្សាភិបាលនីមួយៗ ត្រូវមានបញ្ជាក់អំពីអាណត្តិ ដែលសមាជិកនោះត្រូវទទួល។

សមាជិកក្រុមប្រឹក្សាភិបាលថ្មី ដែលត្រូវបានតែងតាំងជំនួសកន្លែងទំនេរ ស្របតាមលក្ខខណ្ឌខាងលើ មានអាណត្តិត្រឹមអាណត្តិ ដែលនៅសល់របស់សមាជិកក្រុមប្រឹក្សាភិបាល។

មុខងារជាប្រធានក្រុមប្រឹក្សាភិបាល **គ.ស.អ.** មានវិសមិតភាពជាមួយមុខងារជាអគ្គនាយក **គ.ស.អ.**។

លើកលែងប្រធានក្រុមប្រឹក្សាភិបាល មុខងារជាសមាជិកក្រុមប្រឹក្សាភិបាល មានវិសមិតភាពមុខងារជាសមាជិករាជរដ្ឋាភិបាល សមាជិករដ្ឋសភា និងសមាជិកព្រឹទ្ធសភា។

ការទទួលខុសត្រូវផ្នែករដ្ឋប្បវេណី ក្នុងក្របខ័ណ្ឌនៃការអនុវត្តមុខងារជាសមាជិកក្រុមប្រឹក្សាភិបាល ត្រូវជាបន្ទុករបស់ **គ.ស.អ.** នោះ លើកលែងតែករណីដែលសមាជិកនោះ បានប្រព្រឹត្តកំហុសដោយចេតនា ឬដោយធ្វេសប្រហែសធ្ងន់ធ្ងរ។

សមាជិកក្រុមប្រឹក្សាភិបាលត្រូវទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ចំពោះបទល្មើសដែលខ្លួនបានប្រព្រឹត្ត។

សមាជិកក្រុមប្រឹក្សាភិបាល មានកាតព្វកិច្ចចូលរួមប្រជុំតាមការអញ្ជើញ ប្រកាន់ខ្ជាប់នូវគោលជំហរ រាយការណ៍ជាប្រចាំពីសកម្មភាពការងារក្នុងក្របខ័ណ្ឌនៃសមត្ថកិច្ចរបស់ខ្លួនជូនក្រសួង ស្ថាប័ន ដែលខ្លួនតំណាងឱ្យ គោរពក្រមសីលធម៌វិជ្ជាជីវៈ គោរពវិន័យ និងបទបញ្ជាផ្ទៃក្នុងរបស់ **គ.ស.អ.**។

**មាត្រា១៣.-ថ្មី**

**គ.ស.អ.** ត្រូវគ្រប់គ្រងដោយអគ្គនាយក **១**រូប ជាមន្ត្រីមកពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលត្រូវតែងតាំង និងបញ្ចប់មុខតំណែងដោយព្រះរាជក្រឹត្យ តាមសំណើរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**គ.ស.អ.** មានអគ្គនាយករង **១**រូប ជាជំនួយការ ជាមន្ត្រីមកពីក្រសួងទេសចរណ៍ ដែលត្រូវតែងតាំង និងបញ្ចប់មុខតំណែងដោយអនុក្រឹត្យ តាមសំណើរបស់ក្រសួងទេសចរណ៍។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវរៀបចំសំណើជូននាយករដ្ឋមន្ត្រី ដើម្បីស្នើតែងតាំងអគ្គនាយក និងអគ្គនាយករងនៃ **គ.ស.អ.**។

មុខងារជាអគ្គនាយក មានវិសមិភាពជាមួយមុខងារជាសមាជិករាជរដ្ឋាភិបាល សមាជិកសភា សមាជិកព្រឹទ្ធសភា និងជាមួយមុខងារជាប្រធានក្រុមប្រឹក្សាភិបាល។

យ៉ាងយូរ ១ (មួយ) ខែក្រោយការតែងតាំងអគ្គនាយក **គ.ស.អ.** ត្រូវរៀបចំរចនាសម្ព័ន្ធគ្រប់គ្រង **គ.ស.អ.** ដោយប្រកាសរួម ដើម្បីដាក់ជូនក្រសួងអាណាព្យាបាលទាំងពីរ ពិនិត្យ និងសម្រេច។

**មាត្រាពីរ:**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៤:**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ៦រោច ខែ ជេស្ឋ ឆ្នាំ ថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៩ ខែ មិថុនា ឆ្នាំ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រីក្រសួងទេសចរណ៍**

**ថោង ខុន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ